**STEPBRIDGE ADAPTED EDUCATIONAL LEARNING CENTRE**

**TERMS AND CONDITIONS**

The following TERMS AND CONDITIONS apply to all Stepbridge members, staff, parents / other family members and guardians of the child-. Stepbridge reserves the right to modify its policy by informing all members and adherents.

The children helped by Stepbridge are under the age of 18, according to the United Nations Convention on the Rights of the Child.

**Stepbridge members and staff**

Anyone joining Stepbridge´s staff gives all the necessary information regarding his identity and address, professional qualifications, an extract from the criminal record.

Any modification in these information and documents should be reported to Stepbridge´s coordinator as soon as possible.

Stepbridge members, staff (coordinator, teachers, teacher assistants, helpers) undertake to provide the centre services in accordance with the needs and expectations of the child and his parents. They will establish with the parents a work program according to the child's difficulties and capacities. They can provide any useful advice for the purpose of helping the child and his parents to overcome the difficulties encountered in the school learning and at home. The predefined program may be (re) evaluated according to the development and progress made by the child.

Stepbridge members and staff undertake to be punctual, neat, to abstain from smoking or to consume alcohol during their services.

In case of incapacity, any staff member should inform Stepbridge´s coordinator immediately.

The staff is not authorized to represent, sign a contract or any other undertaking on behalf of Stepbridge, unless duly authorized to do so.

No verbal and / or physical violence or inappropriate language against the child or other family member is tolerated. The staff must respect the dignity and integrity of the child and his family. Any other form of abuse is prohibited in accordance with the United Nations Convention on the Rights of the Child, the Cambodian Constitution and all other Cambodian laws and regulations regarding the rights of the child.

Members and staff must respect the privacy of families. Taking pictures requires the prior consent of the parents. Any pictures taken as part of the services can only be used to feed the Facebook page and the website of Stepbridge (www.stepbridge.org). In no case they can be used for private purposes.

In the event of a problem or difficulty encountered, or in the event of damage caused during the performance of their mission, the staff members are required to inform Stepbridge´s coordinator immediately.

Minor children are under the full responsibility of their parents. A medical form with confidential information is filled by the parents. A medical permission form is filled and signed by the parents. In case of illness or incident that occurs in the centre, Stepbridge will immediately contact the family. If no family member can be reached, Stepbridge is authorized to call the required emergency service or to transport the child to an hospital. Stepbridge is responsible in case of an incident that occurs at the centre, due to its fault or negligence.

**Parents / other family members and guardians of the child**

Parents are responsible for their minor children. They agree that in case of emergency (illness or incident that occurs at the centre), Stepbridge can call the required emergency service. Stepbridge is responsible in case of an incident that occurs at the centre, due to its fault or negligence.

In case of incapacity, in case of absence of the child (illness, outdoor appointment…) parents should inform Stepbridge´s coordinator as soon as possible (the day before or the same day **before 7.30 am**).

No verbal and / or physical violence or inappropriate language against Stepbridge´s staff is tolerated. Parents and children are expected to respect the dignity and integrity of the staff. Any other form of abuse is prohibited.

Parents pay an annual enrollment fees of **USD 20**, in order to contribute to the office fees and supplies, purchase of school uniform, supplies and other materials for the proper performance of the centre´s mission. The enrollment fees are an annual charge and should be paid in advance.

The payment of the monthly school fees can be done at the end of the month.

**These regulations are subject to the Cambodian legislation in force.**

## សេចក្តីព្រមព្រៀង និង លក្ខខណ្ឌ នៃមជ្ឈមណ្ឌលសិក្សា STEPBRIDGE

លក្ខខណ្ឌខាងក្រោមអនុវត្តចំពោះរាល់សមាជិកនៃ មជ្ឈមណ្ឌលសិក្សា Stepbridge ដែលរួមមាន៖ បុគ្គលិក ឪពុកម្តាយ/សមាជិកគ្រួសារផ្សេងទៀត និងអាណាព្យាបាលរបស់កុមារ។ មជ្ឈមណ្ឌលសិក្សា Stepbridge រក្សាសិទ្ធិក្នុងការកែប្រែគោលការណ៍របស់មជ្ឈមណ្ឌល ដោយជូនដំណឹងដល់សមាជិក និងបុគ្គលពាក់ព័ន្ធទាំងអស់។

កុមារដែលជួយដោយ មជ្ឈមណ្ឌលសិក្សា Stepbridge ត្រូវមានអាយុក្រោម 18 ឆ្នាំ ដោយយោងទៅតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ។

### សម្រាប់សមាជិក និង បុគ្គលិកនៃ មជ្ឈមណ្ឌលសិក្សា Stepbridge

រាល់បុគ្គលដែលចូលរួមជាបុគ្គលិករបស់ មជ្ឈមណ្ឌលសិក្សា Stepbridge ត្រូវផ្តល់ព័ត៌មានចាំបាច់ទាំងអស់ ដែលទាក់ទងនឹងអត្តសញ្ញាណ អាស័យដ្ឋាន គុណវុឌ្ឍិវិជ្ជាជីវៈ និង លិខិតបញ្ជាក់កំណត់ត្រាឧក្រិដ្ឋកម្មព្រហ្មទណ្ឌ។

រាល់ការកែប្រែទៅលើទិន្នន័យ និងឯកសារទាំងអស់ត្រូវតែ ធ្វើសេចក្តីរាយការណ៍ទៅអ្នកសម្របសម្រួលរបស់មជ្ឈមណ្ឌលសិក្សា Stepbridge ឱ្យបានរហ័សតាមដែលអាចធ្វើទៅបាន។

រាល់សមាជិកនៃ មជ្ឈមណ្ឌលសិក្សា Stepbridge រួមមាន បុគ្គលិក (អ្នកសម្របសម្រួល គ្រូបង្រៀន ជំនួយការគ្រូបង្រៀន ជំនួយការ) ត្រូវប្រកាន់ខ្ជាប់នូវក្នុងការផ្តល់សេវាកម្ម ដែលសមស្របទៅតាមតម្រូវការ និងការរំពឹងទុករបស់កុមារ និង អាណាព្យាបាល។ រាល់សមាជិកនៃ មជ្ឈមណ្ឌលសិក្សា Stepbridge នឹងបង្កើតកម្មវិធីអប់រំ ជាមួយនឹងឪពុកម្តាយ ដោយផ្អែកទៅលើការលំបាក និង សមត្ថភាពរបស់កុមារ ព្រមទាំងផ្តល់យោបល់ដែលមានប្រយោជន៍ក្នុងគោលបំណងជំនួយដល់កុមារ និងឪពុកម្តាយឱ្យសម្រេចនូវរាល់បញ្ហា ក្នុងការសិក្សាទាំងនៅសាលា និងនៅផ្ទះ។ កម្មវិធីដែលបានរៀបចំឡើងនេះ អាចនឹងត្រូវធ្វើការវាយតម្លៃ (ឡើងវិញ) យោងទៅតាមការអភិវឌ្ឍន៍ និងភាពរីកចម្រើនរបស់កុមារ។

រាល់សមាជិក និងបុគ្គលិករបស់ មជ្ឈមណ្ឌលសិក្សា Stepbridge ត្រូវប្រកាន់ខ្ជាប់នូវពេលវេលា អនាម័យ ព្រមទាំងចៀសវាងការជក់បារី ឬប្រើប្រាស់គ្រឿងស្រវឹងក្នុងអំឡុងពេលប្រតិបត្តការងារ។

ក្នុងករណីមិនអាចបំពេញការងារបាន រាល់បុគ្គលិកត្រូវតែជូនដំណឹងទៅអ្នកសម្របសម្រួលរបស់ មជ្ឈមណ្ឌលសិក្សា Stepbridge ជាបន្ទាន់។

បុគ្គលិកមិនត្រូវបានអនុញ្ញាតឱ្យធ្វើជាតំណាង ចុះហត្ថលេខាលើកិច្ចសន្យា ឬកិច្ចព្រមព្រៀងណាមួយ នៅក្នុងនាមជាអ្នកទំណាងឱ្យ មជ្ឈមណ្ឌលសិក្សា Stepbridge នោះទេ លុះត្រាតែមានការអនុញ្ញាត និង ការចាត់តាំងត្រឹមត្រូវ។

មជ្ឈមណ្ឌលសិក្សា Stepbridge នឹងមិនយោគយល់ទៅលើរាល់ សកម្មភាពហឹង្សា ដោយពាក្យសម្តី និង/ឬកាយវិការ ឬការប្រើប្រាស់ភាសាមិនសមរម្យដែលធ្វើឱ្យប៉ះពាល់ដល់កុមារ ឬសមាជិកគ្រួសារផ្សេងទៀតឡើយ។ គ្រប់បុគ្គលិកត្រូវប្រកាន់ខ្ជាប់នូវការគោរព ឱ្យតម្លៃ និង គោរពនូវភាពត្រឹមត្រូវ របស់កុមារ និងក្រុមគ្រួសារ។ រាល់សកម្មភាព

នៃការរំលោភបំពានគ្រប់រូបភាព ត្រូវបានហាមឃាត់ ដោយអនុលោមតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៃ រដ្ឋធម្មនុញ្ញកម្ពុជា ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិ ផ្សេងៗទៀតរបស់កម្ពុជាដែលទាក់ទងនឹងសិទ្ធិកុមារ។

រាល់សមាជិក និងបុគ្គលិកត្រូវគោរពភាពឯកជនរបស់គ្រួសារ។ រាល់ការថតរូប ត្រូវទាមទារឱ្យមាន ការយល់ព្រមពីជាមុនឪពុកម្តាយ។ គ្រប់រូបភាពដែលត្រូវបានថតឡើង ដែលជាផ្នែកនៃសកម្មភាពក្នុងកំឡុងពេលបម្រើសេវាកម្មអប់រំ អាចប្រើដើម្បីផ្តល់ជាព័ត៌មានដល់គេហទំព័រ Facebook និងគេហទំព័ររបស់ មជ្ឈមណ្ឌលសិក្សា Stepbridge (www.stepbridge.org) តែប៉ុណ្ណោះ។ មិនថាក្នុងករណីណាក៏ដោយ រាល់រូបភាពទាំងអស់មិនអាចយកទៅប្រើប្រាស់សម្រាប់គោលបំណងឯកជននោះឡើយ។

ក្នុងករណីមានបញ្ហា ឬជួបប្រទះការលំបាក ឬក្នុងករណីមានការខូចខាតអំឡុងពេលបំពេញការងារ សមាជិក និងបុគ្គលិកត្រូវជូនដំណឹងទៅកាន់អ្នកសម្របសម្រួលរបស់ មជ្ឈមណ្ឌលសិក្សា Stepbridge ជាបន្ទាន់។

ដោយកុមារតូចៗនៅស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់ឪពុកម្តាយនៅឡើយ ឪពុកម្តាយត្រូវបំពេញ នូវរាល់ទម្រង់បែបបទផ្នែកវេជ្ជសាស្ត្រដែលមានព័ត៌មានដែលត្រូវរក្សាជាការសម្ងាត់ផ្សេងៗ។ ទម្រង់បែបបទអនុញ្ញាតវេជ្ជសាស្ត្រត្រូវធ្វើការបំពេញ និងចុះហត្ថលេខាដោយឪពុកម្តាយ។ ក្នុងករណីមានជំងឺ ឬ ឧបទ្ទវហេតុដែលកើតឡើងនៅមណ្ឌលសិក្សា Stepbridge ខាងមណ្ឌលសិក្សា នឹងទាក់ទងទៅក្រុមគ្រួសារភ្លាមៗ។ ប្រសិនបើ មិនអាចទាក់ទងសមាជិកគ្រួសារណាម្នាក់បាន មណ្ឌលសិក្សា Stepbridge ត្រូវបានប្រគល់សិទ្ធ ក្នុងការទាក់ទងទៅកាន់សេវាសង្គ្រោះបន្ទាន់ ឬបញ្ជូនកុមារទៅកាន់មន្ទីរពេទ្យ។ មណ្ឌលសិក្សា Stepbridge នឹងទទួលខុសត្រូវក្នុងករណីដែលមានឧប្បត្តិហេតុ កើតឡើងនៅក្នុង មណ្ឌលសិក្សា Stepbridge ដោយសារកំហុស ឬការធ្វេសប្រហែសរបស់ខាងមណ្ឌល។

## ឪពុកម្តាយ/សមាជិកគ្រួសារផ្សេងទៀត និងអាណាព្យាបាលរបស់កុមារ

កុមារដែលនៅជា អនីតិជន គឺនៅស្ថិតក្រោមទំនួលខុសត្រូវរបស់ឪពុកម្តាយនៅឡើយ ដូចនេះឪពុកម្តាយត្រូវផ្តល់នូវការអនុញ្ញាតឱ្យ មណ្ឌលសិក្សា Stepbridge ទូរស័ព្ទទៅសេវាសង្គ្រោះបន្ទាន់ ក្នុងករណីមានអាសន្ន (ជំងឺ ឬ ឧបទ្ទវហេតុដែលកើតឡើងនៅមជ្ឈមណ្ឌល) មណ្ឌលសិក្សា Stepbridge នឹងទទួលខុសត្រូវក្នុងករណីដែលមានឧប្បត្តិហេតុ កើតឡើងនៅក្នុង មណ្ឌលសិក្សា Stepbridge ដោយសារកំហុស ឬការធ្វេសប្រហែសរបស់ខាងមណ្ឌល។

ក្នុងករណីមិនអាចមកសាលា ឬ អវត្តមានរបស់កុមារ (ដោយសារជំងឺ ការណាត់ជួបក្រៅផ្ទះផ្សេងៗ) ឪពុកម្តាយគួរតែជូនដំណឹងដល់អ្នកសម្របសម្រួលរបស់ Stepbridge ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន (នៅមុនថ្ងៃអវត្តមាន ឬ ថ្ងៃដដែលមុនម៉ោង 7.30 ព្រឹក)។

មជ្ឈមណ្ឌលសិក្សា Stepbridge នឹងមិនយោគយល់ទៅលើរាល់ សកម្មភាពហឹង្សា ដោយពាក្យសម្តី និង/ឬ កាយវិការ ឬការប្រើប្រាស់ភាសាមិនសមរម្យដែលធ្វើឱ្យប៉ះពាល់ដល់ បុគ្គលិករបស់មជ្ឈមណ្ឌលសិក្សា Stepbridge

នោះឡើយ ។ ឪពុកម្តាយ និង សិស្ស ត្រូវគោរព ឱ្យតម្លៃ និង គោរពនូវភាពត្រឹមត្រូវ របស់បុគ្គលិក។ រាល់សកម្មភាពនៃការរំលោភបំពានគ្រប់រូបភាព ត្រូវបានហាមឃាត់។

មាតាបិតាត្រូវ បង់ថ្លៃចុះឈ្មោះចូលរៀនប្រចាំឆ្នាំចំនួន 20 ដុល្លារអាមេរិក ជាមុន ដើម្បីចំណាយទៅលើថ្លៃរដ្ឋបាល និងការផ្គត់ផ្គង់ផ្សេងៗ ថ្លៃឯកសណ្ឋានសាលា សម្ភារៈប្រើប្រាស់ និងឧបករណ៍ ផ្សេងទៀតសម្រាប់ការអនុវត្តសកម្មភាពសិក្សា។

ការបង់ថ្លៃសិក្សាប្រចាំខែអាចធ្វើឡើងនៅរៀងរាល់ចុងខែ។

**បទប្បញ្ញត្តិទាំងនេះស្ថិតនៅក្រោមច្បាប់របស់កម្ពុជាជាធរមាន។**

**DECLARATION (PARENTS)**

**សេចក្ដីប្រកាស (ឪពុកម្ដាយ)**

By signing this declaration, you are stating that you have read, understood and agreed to abide by its content.

តាមរយៈការចុះហត្ថលេខាលើសេចក្ដីប្រកាសនេះ លោកអ្នកកំពុងបញ្ជាក់ថាលោកអ្នកបានអាន យល់ និង យល់ព្រមគោរពតាមខ្លឹមសាររបស់សេចក្ដីប្រកាសនេះ។

I (name and address)\ខ្ញុំបាទ\នាងខ្ញុំ(ឈ្មោះ និង តួនាទី)

Declare that\ប្រកាសថា:

I have read and understood the Stepbridge TERMS AND CONDITIONS.

I am aware that a copy of these TERMS AND CONDITIONS is available on site at Stepbridge office and on the Stepbridge website (www.stepbridge.org).

ខ្ញុំបានអាន និងយល់ពីកិច្ចព្រមព្រៀង និង លក្ខខណ្ឌរបស់ មជ្ឈមណ្ឌលសិក្សា Stepbridge ។

ខ្ញុំដឹងថាច្បាប់ចម្លងនៃលក្ខខណ្ឌទាំងនេះមាននៅលើ គេហទំព័រនៃការិយាល័យរបស់មជ្ឈមណ្ឌលសិក្សា Stepbridge និងនៅលើគេហទំព័រ Stepbridge (www.stepbridge.org)។

Date\កាលបរិច្ឆេទ:

Signature\ហត្ថលេខា: